# តារាងពត៌មានអំពីការចូលរួមរបស់ជនរងគ្រោះ

## ការចូលរួមរបស់ជនរងគ្រោះ

តាមរយៈការបំពេញទម្រង់ការចូលរួមដោយជនរងគ្រោះ ជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យអាចស្នើសុំចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការជំនុំជម្រះក្ដីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមរបៀបបីយ៉ាងៈ តាមរយៈការស្ម័គ្រចិត្តធ្វើជា**សាក្សី**, តាមរយៈការដាក់**ពាក្យបណ្ដឹង**, និង តាមរយៈការដាក់ពាក្យចូលរួមជា«ជនរងគ្រោះ» នៅក្នុង**បណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី** ។

លោកអ្នកគួរតែដឹងថា ភាគច្រើននៃជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់នឹងមិនត្រូវបានគេជ្រើសយកធ្វើជាសាក្សីទេ ។ ជាងនេះទៅទៀត ភាគច្រើននៃពាក្យបណ្ដឹង និងបណ្ដឹងសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី នឹងទំនងជាត្រូវច្រានចោល ។ នេះមិនមែនមានន័យថា ពត៌មានដែលលោកអ្នកបានផ្ដល់ឲ្យ ឬ ការរងគ្រោះដែលលោកអ្នកទទួលរង មិនសំខាន់នោះទេ ។ វាក៏មិនមានន័យថា អង្គជំនុំជម្រះវិសាមញ្ញ មិនជឿជាក់លោកអ្នក ឬមិនផ្ដល់តម្លៃចំពោះរឿងរ៉ាវរបស់លោកអ្នកនោះទេ ។ វាគ្រាន់តែមានន័យថា ដោយសារអង្គជំនុំជម្រះវិសាមញ្ញមានធនធាន និងពេលវេលាមានកំណត់ និងជំនុំជម្រះតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងរយៈកាលពីឆ្នាំ១៩៧៥-១៩៧៩ ជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់មកលើរូបលោកអ្នកប្រហែលជាមិនត្រូវចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញទេ ហើយការរងគ្រោះរបស់លោកអ្នកផ្ទាល់ខ្លួននឹងប្រហែលជាមិនត្រូវបានលើកយកពិភាក្សាដោយអង្គជំនុំជម្រះវិសាមញ្ញ ។

ប៉ុន្តែ សំណើរសុំចូលរួមរបស់លោកអ្នក នឹងក្លាយជាផ្នែកមួយនៃឯកសារប្រវត្តិសាស្ត្រ និងបានរួមចំណែកដល់ការយល់ដឹងរបស់យើងទាក់ទងនឹងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងរយៈពេលនោះ ។ ដូចគ្នាដែរ លោកអ្នកអាចបន្តរួមចំណែកដល់ដំណើរការផ្សះផ្សាជាតិ តាមរយៈការសម្ដែងយោបល់អំពីប្រភេទនៃការជួសជុលសំណងជាសមូហភាព ឬជានិមិត្តរូប ដែលលោកអ្នកចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញ ផ្ដល់ឲ្យជនរងគ្រោះនៅចុងបញ្ចប់នៃដំណើរការជំនុំជម្រះ ។

Documentation Center of Cambodia
Searching for the Truth ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

## ទំនាក់ទំនងអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញ

អង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញគឺជាកន្លែងសម្រាប់ទំនាក់ទំនងតែមួយគត់សម្រាប់ជនរងគ្រោះដែលដាក់ពាក្យសុំចូលរួមនៅក្នុងដំណើរការជំនុំជម្រះ ។ អាស័យដ្ឋានរបស់អង្គភាពជនរងគ្រោះ:


អង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញ

ផ្លូវជាតិលេខ៤

សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ ប្រទេសកម្ពុជា

អ៊ីម៉េល: victimsunit@eccc.gov.kh


## តួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជាអាចជួយជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យយល់ដឹងអំពីសិទ្ធិក្នុងការចូលរួម និងជួយជនរងគ្រោះទាំងនេះចុះឈ្មោះជាមួយអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងមិនផ្តល់តំណាងផ្នែកច្បាប់ ឬជំនួយជាបន្តបន្ទាប់ពេញរយៈពេលជំនុំជម្រះទាំងស្រុងនោះទេ ។


ពត៌មានបន្ថែមសូមទាក់ទង

វ៉ាន់ថាន់ ពោធិដារ៉ា

នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា

ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ

ទូរស័ព្ទលេខ : ០២៣ ២១១ ៨៧៥

ទូរស័ព្ទដៃលេខ : ០១២ ៨៤៦ ៥២៦

ទូរសារលេខ : ០២៣ ២១០ ៣៥៨

អ៊ីម៉ែល : truthpdara@yahoo.com

គេហទំព័រមជ្ឈមណ្ឌលឯកសារកម្ពុជា www.dccam.org



ប្រែសម្រួលជាភាសាខ្មែរដោយជី ទេរិទ្ធិ មជ្ឈមណ្ឌលឯកសារកម្ពុជា